**នៅចំពោះមុខ អង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ)

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សំ សុគង់

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៧

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 18-Aug-2017, 12:30
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ អ.ប.ជ: **សម្ងាត់/Confidential**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាត ដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា អន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ**

---

__ដាក់ដោយ៖__

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

សំ សុគង់

__ផ្ញើជូន៖__

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម BAIK Kang Jin

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា**

ជា លាង

Nicolas KOUMJIAN

**សហមេធាវីការពារក្តី អ៊ឹម ចែម**

ប៊ិត ស៊ាងលីម

Wayne JORDASH

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**
**នៅក្នុងសំណុំរឿង ០០៤/១**

១. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សូមស្នើសុំអង្គបុរេជំនុំជម្រះ អនុញ្ញាតឲ្យគាត់ពន្យារពេលក្នុងការដាក់ចម្លើយតបទៅនឹង*បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* (បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ)[1] យោងតាមវិធានផ្ទៃក្នុង ៣៩(៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ យោងតាមមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក (សេចក្តីណែនាំអនុវត្ត) [2] សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ ក៏សូមស្នើសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ តែជាភាសាអង់គ្លេសសិន ដោយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយក្នុងពេលឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

២. សំណើសុំពន្យារពេលនេះមានយុត្តិកម្មសំអាងហេតុជាចាំបាច់។ នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ក.ស.ច.ស បានចេញ*ដីកាដំណោះស្រាយ(សំអាងហេតុ)* (ដីកាសម្រេចរបស់ ក.ស.ច.ស)[3] ដោយរកឃើញថា អ៊ឹម ចែម មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ។ សំណៅជាភាសាអង់គ្លេសនៃដីកាសម្រេចរបស់ ក.ស.ច.ស មាន ១៣២ ទំព័រ ជាង ៣២៥ កថាខណ្ឌ មិនរាប់ឧបសម្ព័ន្ធទេ។ បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ដែលលើកឡើងពីបញ្ហាយុត្តាធិការបុគ្គល បានដាក់នៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧ ហើយមាន ២៩ ទំព័រជាភាសាអង់គ្លេស (ខ្វះមួយទំព័រនៃចំនួនទំព័រ ៣០ ជាអតិបរមាដែលអនុញ្ញាតតាមមាត្រា ៥.២ នៃសេចក្តីណែនាំអនុវត្ត)។ ទាំង ដីកាសម្រេចរបស់ ក.ស.ច.ស ទាំង បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ លើកឡើងពីបញ្ហាស្មុគស្មាញទាក់ទងនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក (ឬកង្វះយុត្តាធិការបុគ្គល) ដែលមានបញ្ហាពាក់ព័ន្ធយ៉ាងច្រើនសម្រាប់សារណាដែលដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើង។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សូមស្នើថា គាត់ត្រូវការពេលវេលាថែមទៀត ហួសពីក្របខណ្ឌពេលវេលារយៈពេលខ្លីដែលមានតែចំនួន ១០ ថ្ងៃ ដូចបានកំណត់នៅក្នុងមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្ត[4] ដើម្បី ធ្វើការឆ្លើយតបឲ្យបានត្រឹមត្រូវទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ជាពិសេសដោយសារថាមានការថយចុះនូវធនធានដែលសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទទួលបាននាពេលបច្ចុប្បន្ន

---

[1] **D308/3/1/1**បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)។

[2] អ.វ.ត.ក/០១/២០០៧/វ៉.០៨ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១២។

[3] **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧។

[4] អ.វ.ត.ក/០១/២០០៧/វ៉.០៨ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១២។

នេះ។ ការមិនអនុញ្ញាតតាមសំណើ នឹងធ្វើឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបាត់បង់នូវឱកាសបញ្ចេញមតិយោបល់របស់ខ្លួនអំពីបញ្ហាស្នូលនៃយុត្តាធិការបុគ្គល ដូចដែល ក.ស.ច.ស បានបកស្រាយនៅក្នុងសំណុំរឿង ០០៤/១។ ជាងនេះទៀត ការអនុញ្ញាតតាមសំណើសុំពន្យារពេលនេះ មិនបណ្ដាលឲ្យមានការពន្យារពេលដែលមិនចាំបាច់នៅក្នុងសំណុំរឿង ០០៤/១ ទេ ហើយក៏មិនធ្វើឲ្យមានផលប៉ះពាល់មិនសមស្របមកលើផលប្រយោជន៍របស់ភាគីដែរ ជាពិសេសដោយសារថា បច្ចុប្បន្ននេះ អ៊ឹម ចែម មិនបានជាប់ឃុំឃាំងឡើយ។

៣. បន្ថែមពីលើនេះទៀត សំណើសុំដាក់ចម្លើយតបជាភាសាអង់គ្លេសិន មានយុត្តិកម្មតាមកាលៈទេសៈពិសេស។ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាតិ មិនមានធនធានផ្ទៃក្នុងដែលមានសមត្ថភាពបកប្រែចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ ទេ។ អង្គភាពបកប្រែភាសារបស់ អ.វ.ត.ក បានបង្ហាញថា ដោយសារបន្ទុកការងារបច្ចុប្បន្ននេះ ខ្លួនមិនអាចចាប់ផ្ដើមបកប្រែចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ រហូតទាល់តែខែ វិច្ឆិកា ឆ្នាំ ២០១៧ យ៉ាងលឿនបំផុត ដូចមានបញ្ជាក់នៅក្នុងអ៊ីមែលដែលបានភ្ជាប់ជូននេះ[5]។

៤. យោងតាមសំអាងហេតុខាងលើនេះ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាតិ សូមស្នើសុំ អង្គបុរេជំនុំជម្រះ ពន្យារពេលក្នុងការដាក់ចម្លើយតបរហូតដល់ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៧ ហើយអនុញ្ញាតឲ្យដាក់ចម្លើយតបជាភាសាអង់គ្លេសសិន ដោយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយយ៉ាងឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

ដោយសេចក្ដីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៧ | សំ សុគង់<br>សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាតិ | ភ្នំពេញ<br>ប្រទេសកម្ពុជា | |

[5] អ៊ីមែលពីអង្គភាពបកប្រែភាសា (ឯកសារភ្ជាប់ជាមួយ ក)។